ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ ៨២៩៧ កបទ.សអ/ច្បក២

ជម្រាបមក
ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និង
កុងស៊ុលកិត្តិយស នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស

**កម្មវត្ថុ៖** ការលុបការហាមឃាត់អ្នកដំណើរមកពីប្រទេសចំនួន១០ នៅទ្វីបអាហ្វ្រិកចូលមកប្រទេសកម្ពុជា។

**យោង៖** - សេចក្តីជូនដំណឹងលេខ ៥២២ សខល ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល។
- លិខិតក្រសួងលេខ ៨០២៨ កបទ.សអ/ច្បក២ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១។

ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស ថា ក្រសួងសុខាភិបាល បានសម្រេចលុបការហាមឃាត់ការធ្វើដំណើរចូលប្រទេសកម្ពុជា ចំពោះអ្នកដំណើរ ឬអ្នកដែលបានឆ្លងកាត់ប្រទេសចំនួន១០ នៅទ្វីបអាហ្វ្រិក (Botswana, Eswatini, Lesotho, Mozambique, Namibia, South Africa, Zimbabwe, Malawi, Angola, និង Zambia) ឬមានប្រវត្តិធ្វើដំណើរទៅប្រទេសទាំង១០នោះ ក្នុងអំឡុងពេល ៣សប្តាហ៍មុនចូលមកប្រទេសកម្ពុជា។

ការលុបចោលវិធានការខាងលើ នឹងត្រូវដាក់ជំនួសមកវិញដោយការអនុវត្តនីតិវិធីបន្ថែមលើនីតិវិធីប្រតិបត្តិស្តង់ដារ Standard Operating Procedures (SOPs) ដើម្បីគ្រប់គ្រងអ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា អនុលោមតាមការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ សម្រាប់អ្នកដំណើរ ឬអ្នកដែលបានឆ្លងកាត់ប្រទេសចំនួន១០ ខាងលើ ឬបណ្តាប្រទេសផ្សេងទៀតដែលត្រូវបានចាត់ទុកជា "ប្រទេសដែលមានការព្រួយបារម្ភ" អំឡុងពេល២សប្តាហ៍មុនធ្វើដំណើរចូលប្រទេសកម្ពុជា ដូចមានចែងក្នុងសេចក្តីប្រកាសព័ត៌មានលេខ ៥២២ សខល ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ជូនភ្ជាប់ជាភាសាខ្មែរ និងភាសាអង់គ្លេស (បកប្រែក្រៅផ្លូវការ)។

សូម ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស អនុវត្តតាមការសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ពុធ ៤កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០២១
រដ្ឋមន្ត្រី

ប្រាក់ សុខុន

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

ក្រសួងសុខាភិបាល
លេខ ៥៤២២ ស.ស.ព.ល

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងសុខាភិបាលមានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ដោយបានទទួលការឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ពាក់ព័ន្ធនឹងវីរុសបំប្លែងថ្មី **អូមីក្រុង** (B.1.1.529) ក្រសួងសុខាភិបាលសម្រេចលុបចោលការហាមឃាត់អ្នកដំណើរ ឬអ្នកដែលបានឆ្លងកាត់ប្រទេសចំនួន១០ នៅទ្វីបអាហ្វ្រិក (Botswana, Eswatini, Lesotho, Mozambique, Namibia, South Africa, Zimbabwe, Malawi, Angola, និង Zambia) ឬមានប្រវត្តិធ្វើដំណើរទៅប្រទេសទាំង១០នោះ ក្នុងអំឡុងពេល៣សប្តាហ៍មុនធ្វើដំណើរចូលប្រទេសកម្ពុជា។ ការលុបចោលវិធានការខាងលើ នឹងត្រូវដាក់ជំនួសមកវិញដោយការអនុវត្តនីតិវិធីបន្ថែម លើនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ដើម្បីគ្រប់គ្រងអ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា អនុលោមតាមការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ សម្រាប់អ្នកដំណើរ ឬអ្នកដែលបានឆ្លងកាត់ប្រទេសចំនួន១០ ខាងលើ ឬមានប្រវត្តិធ្វើដំណើរទៅប្រទេសទាំង១០នោះ ឬបណ្តាប្រទេសផ្សេងទៀតដែលត្រូវបានចាត់ទុកថាជា "ប្រទេសដែលមានការព្រួយបារម្ភ" អំឡុងពេល២សប្តាហ៍មុនធ្វើដំណើរចូលប្រទេសកម្ពុជា ដូចខាងក្រោម៖

១-អ្នកដំណើរដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ត្រូវបង្ហាញវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ (តេស្ត PCR) ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី ឬប្រទេសសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា៖

ក- ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅពេលមកដល់

- ក្នុងករណីទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ វិជ្ជមាន ត្រូវយកសំណាកធ្វើតេស្ត PCR បញ្ជាក់ និងត្រូវធ្វើចត្តាឡីស័កដាច់ដោយឡែកនៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចៈ
  - ក្នុងករណីទទួលបានលទ្ធផលតេស្ត PCR វិជ្ជមាន ត្រូវធ្វើការព្យាបាល
  - ក្នុងករណីទទួលបានលទ្ធផលតេស្ត PCR អវិជ្ជមាន ត្រូវបន្តធ្វើចត្តាឡីស័កដាច់ដោយឡែករយៈពេល៧ថ្ងៃ និងធ្វើតេស្ត PCR នៅថ្ងៃទី៦ នៃការធ្វើចត្តាឡីស័ក។
- ក្នុងករណីទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ អវិជ្ជមាន ត្រូវធ្វើចត្តាឡីស័ករយៈពេល៧ថ្ងៃ និងធ្វើតេស្ត PCR នៅថ្ងៃទី៦ នៃការធ្វើចត្តាឡីស័ក។

ខ- អ្នកដំណើរជាជនបរទេសត្រូវកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ករយៈពេល៧ថ្ងៃ។ ក្នុងករណីអ្នកដំណើរមិនបានកក់សណ្ឋាគារត្រូវទៅកាន់បញ្ជរធនាគារ ដើម្បីតម្កល់ប្រាក់១.០០០ (មួយពាន់) ដុល្លារអាមេរិក ⁄

សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័ករយៈពេល ៧ថ្ងៃ នៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមូលដ្ឋាន។

២-អ្នកដំណើរដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ត្រូវបង្ហាញវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ (តេស្ត PCR) ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី ឬប្រទេសសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា។

អ្នកដំណើរដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ដោយអនុវត្តតាមនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ដើម្បីគ្រប់គ្រងអ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា អនុលោមតាមការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។

៣-អ្នកដំណើរជាជនបរទេសត្រូវបានលើកទឹកចិត្តឱ្យមានបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (COVID-19 Health Insurance Policy) ដែលនៅកម្ពុជាអាចទិញពីការធានារ៉ាប់រងរួមគ្នា (Insurance Consortium) តំណាងដោយក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/ ។

សេចក្តីប្រកាសព័ត៌មាននេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអាទិត្យ ១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ
-អនុគណៈកម្មការគ្រប់គ្រងច្រកចេញចូលប្រទេស និងការធ្វើចត្តាឡីស័ក
-ឯកសារ-កាលប្បវត្តិ

*( Unofficial Translation )*

KINGDOM OF CAMBODIA

NATION RELIGION KING

* * * * *

( Logo )

Ministry of Health

No. 522 សខណ

# PRESS RELEASE

* * * * *

The Ministry of Health is honored to inform that in compliance with the high approval of **Samdech Akka Moha Sena Padei Techo HUN SEN,** Prime Minister of the Kingdom of Cambodia, regarding the new coronavirus variant, B.1.1.529, ), the Ministry of Health decided to lift the ban on travelers or those who have passed through ten countries in Africa ( Botswana, Eswatini, Lesotho, Mozambique, Namibia, South Africa, Zimbabwe, Malawi, Angola, and Zambia ) or those with travel history to the ten counties within the last three weeks before entering Cambodia. The abolishment of the above measures will be replaced by the implementation of additional procedures on standard operating procedures ( SOPs ) to manage travelers arriving at the International Airports in Cambodia in accordance with the new normal context of COVID-19 for travelers or those who have passed through the above 10 countries or other countries that are considered as "countries of concern" within the last two weeks before entering Cambodia as follows:

1. Travelers who have been fully vaccinated the COVID-19 vaccine shall present the certificate indicating negative for COVID-19 ( PCR test ) within the validity of 72 hours prior arriving in Cambodia recognized by the health authority of the host country or last resident country before departure for Cambodia:
   a. Shall take COVID-19 antigen rapid test upon arrival
      - In case of receiving positive COVID-19 antigen rapid test result, a PCR test sample shall be taken and the traveler shall undertake quarantine at the location designated by the Ministry of Health or competent authorities:
        - In case of a positive PCR test result, treatment is required.
        - In case of a negative PCR test result, quarantine is required for 7 days and PCR test is performed on the 6th day of quarantine.
      - In case of a negative COVID-19 antigen rapid test result, quarantine is required for 7 days and PCR test is performed on the 6th day of quarantine.
   b. Foreign travelers shall book a hotel for a 7-day quarantine. If the traveler does not book the hotel, he/she shall go to the bank counter to deposit 1,000 ( one thousand ) US dollars to guarantee all the expenses during the 7-day quarantine at the location designated by the Ministry of Health or local authorities.

2. Travelers who have not been fully vaccinated the COVID-19 vaccine shall present the certificate indicating negative for COVID-19 (PCR test) within the validity of 72 hours prior arriving in Cambodia recognized by the health authority of the host country or last resident country before departure for Cambodia.

   The travelers who have not been fully vaccinated the COVID-19 vaccine have to undertake 14-day quarantine, following standard operating procedures (SOPs) to manage travelers arriving at the International Airports in Cambodia in accordance with the new normal context of COVID-19.

3. Foreign travelers are encouraged to have a COVID-19 Health Insurance Policy, which in Cambodia can be purchased from the Insurance Consortium, represented by Forte Insurance via website https://www.fortcinsurance.com/covid-19-insurance/.

This press release is taking into effect from the date of signature.

Phnom Penh, 5 December 2021

**Minister of Health and Chair**

**of the Inter-Ministerial Committee to Combat COVID-19**

Signed and Stamped

**MAM BUNHENG**

**Copied to:**

- Office of Council Ministers
-Cabinet of Samdech Techo Prime Minister
- Ministry of Interior
- Ministry of Foreign Affairs and International Cooperation
- State Secretariat of Civil Aviation
- General Department of Immigration of the Ministry of Interior
- Sub-Committee on Gateway Management and Quarantine
- Record-Archives

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៤០២៨ កបទ.សអ/ច្បក២

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស**

**<u>កម្មវត្ថុ</u>៖** ការហាមឃាត់អ្នកដំណើរមកពីប្រទេសចំនួន១០ នៅទ្វីបអាហ្វ្រិកចូលកម្ពុជា។

**<u>យោង</u>៖** សេចក្ដីជូនដំណឹងលេខ ៥១៩ សខល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល។

ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស** ថា ក្រសួងសុខាភិបាល បានសម្រេចហាមឃាត់អ្នកដំណើរ ឬអ្នកដែលបានឆ្លងកាត់ប្រទេសចំនួន១០ នៅទ្វីបអាហ្វ្រិក ឬមានប្រវត្តិធ្វើដំណើរទៅប្រទេសទាំង១០ ក្នុងអំឡុងពេល ៣ សប្ដាហ៍មុនចូលមកប្រទេសកម្ពុជា ធ្វើដំណើរចូលប្រទេសកម្ពុជា ទាំងតាមផ្លូវអាកាស និងផ្លូវគោកមួយរយៈសិន រហូតដល់មានការជូនដំណឹងជាថ្មី ដើម្បីទប់ស្កាត់ការឆ្លងចូលកម្ពុជានូវមេរោគកូវីដ-១៩ថ្មីប្រភេទអូមីក្រុង (Omicron) ដោយចាប់អនុវត្តក្រោយ ៤៨ម៉ោង បន្ទាប់ពីចេញសេចក្ដីប្រកាសព័ត៌មានដូចមានជូនភ្ជាប់។ ប្រទេសទាំង១០នោះ រួមមាន (១) Botswana (២) Eswatini (៣) Lesotho (៤) Mozambique (៥) Namibia (៦) South Africa (៧) Zimbabwe (៨) Malawi (៩) Angola និង (១០) Zambia។

សូម **ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស** អនុវត្តតាមការសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ពុធ ១២រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh